# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

* * * * * * * * * * * * *

## កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ រវាង
## ក្រុមហ៊ុន អិមធីយេស៍ហ្គាមេន ខេមបូឌា ខូអិលធីឌី
## ជាមួយតំណាងកម្មករ សហជីព និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

នៅថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ០៨:០០ ព្រឹក នៅក្នុងរោងចក្រ អិមធីយេស៍ហ្គាមេន មានកិច្ចប្រជុំជាមួយតំណាងក្រុមហ៊ុន និងសហជីព តំណាងកម្មករ និយោជិក។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិកទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលឲ្យសង្វាក់ផលិតកម្មត្រូវផ្អាកកម្មករមួយចំនួន។ ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ៥៥ នាក់ (ស្រី ៤៣ នាក់) រយៈពេល ៣១ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០១ ខែ មករា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែ មករា ឆ្នាំ២០២៤ ដោយរក្សាតួនាទី ភារកិច្ច និងអត្ថប្រយោជន៍កម្មករពេលចូលធ្វើការវិញនៅដដែល ហើយកំឡុងពេលព្យួរកិច្ចសន្យានេះ កម្មករនិយោជិកបានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវទឹកប្រាក់ឧបត្ថម្ភក្នុងមួយខែ ៣០ ដុល្លារសហរដ្ឋអាមេរិច។

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះនឹងបើកជូនបងប្អូនកម្មករ នៅមុនថ្ងៃឈប់សម្រាកព្យួរដែលត្រូវនឹងថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០២៣។ អង្គប្រជុំនេះបានបញ្ចប់នៅវេលាម៉ោង ០៩:២០ នាទីព្រឹក នាថ្ងៃ ខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

ថ្ងៃសៅរ៍ ១១ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ភ្នំពេញ, ថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ២០២៣

**តំណាងកម្មករ និងតំណាងសហជីព**

1- [ព្រាំ បូរិន្ទ]

២. [ប្រាក់ តាញ៉ី]

3- [ទៀម ស្រួយ]

4 [មាស តារាវត្តី]

**នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
... GARMENT ... CO.,LTD
KINGDOM OF CAMBODIA